ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៥៩០ ព.ណ.អ.ផ.អ

# សេចក្តីប្រកាសព័ត៌មាន
## អំពីសេចក្តីសម្រេចរបស់គណៈកម្មការអឺរ៉ុបប្រកាសអំពីដំណើរការនីតិវិធី ឈានទៅពិនិត្យលទ្ធភាពព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធក្រោមកម្មវិធី «គ្រប់មុខទំនិញលើកលែងតែសព្វាវុធ (EBA)»

ក្រោយពីបានទទួលលិខិតលេខIM/is Ares( 2019) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់លោកស្រី ហ្វេដរីកា ម៉ូហ្គេរីនី អនុប្រធានតំណាងជាន់ខ្ពស់នៃគណៈកម្មការអឺរ៉ុប និងលោកស្រី សេស៊ីលៀ ម៉ុលស្ត្រូម ស្នងការពាណិជ្ជកម្មអឺរ៉ុប និងបន្ទាប់ពីបានពិនិត្យសេចក្តីសម្រេចអនុវត្តលេខ 2019/C 55/07 ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់គណៈកម្មការអឺរ៉ុប ដែលបានចុះផ្សាយជាផ្លូវការលើ Official Journal របស់សហភាពអឺរ៉ុប នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការចាប់ផ្តើមដំណើរការនីតិវិធីព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធក្រោមកម្មវិធី «គ្រប់មុខទំនិញលើកលែងតែសព្វាវុធ (EBA)» រួចមក ព្រមទាំងក្រោយពីបានពិនិត្យឃើញការផ្សព្វផ្សាយព័ត៌មានមិនពិតតាមបណ្តាញសារព័ត៌មានសង្គម ដែលប្រាសចាកពីខ្លឹមសារដើមនៃលិខិត និងសេចក្តីសម្រេចដូចបានលើកឡើងខាងដើម បានធ្វើឲ្យសាធារណជនមានការភ័ន្តច្រឡំ ក្រសួងពាណិជ្ជកម្មសូមធ្វើការស្រាយបំភ្លឺ និងពន្យល់អំពីខ្លឹមសារ និងនីតិវិធី ដូចខាងក្រោម៖

**ខ្លឹមសារសង្ខេបនៃសេចក្តីសម្រេច៖**

- ផ្អែកតាមមាត្រា ១៩ នៃបញ្ញត្តិរបស់សហភាពអឺរ៉ុប លេខ 978/2012 ទាក់ទងនឹងនីតិវិធីសម្រាប់ស៊ើបអង្កេត ដើម្បីឈានទៅធ្វើសេចក្តីសម្រេចចិត្តក្នុងការព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធក្រោមកម្មវិធី EBA ដែលបានផ្តល់ឲ្យបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច កាលពីឆ្នាំ២០១២ និងដើម្បីធានាសង្គតិភាពនៃការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាជាមួយនឹងលក្ខខណ្ឌមានចែងនៅក្នុងបញ្ញត្តិខាងលើឲ្យបានពេញលេញ គណៈកម្មការអឺរ៉ុបបានសម្រេចផ្តួចផ្តើមគំនិតក្នុងការចាប់ផ្តើមនីតិវិធីនេះ ចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ នេះតទៅ តាមរយៈការពិគ្រោះយោបល់ជាមួយកម្ពុជា និងភាគីពាក់ព័ន្ធ។ ការផ្តួចផ្តើមគំនិតនេះ មិនមានន័យថា សហភាពអឺរ៉ុបចាប់ផ្តើមព្យួរប្រព័ន្ធអនុគ្រោះពន្ធភ្លាមៗ ឬជាស្វ័យប្រវត្តិនោះឡើយ តែជាពេលវេលាដែលចាប់ផ្តើមបើកនីតិវិធីពិគ្រោះយោបល់ជាផ្លូវការតែប៉ុណ្ណោះ។

**ខ្លឹមសារសង្ខេបនៃនីតិវិធី៖**

- រយៈពេលគិតចាប់ពីការចាប់ផ្តើម រហូតដល់ការចូលជាធរមាននៃសេចក្តីសម្រេចចុងក្រោយណាមួយ មានចំនួន ១៨ ខែ គិតចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩។
- រយៈពេលខាងលើ ត្រូវបានកំណត់ជា ២ ដំណាក់កាល៖

<u>**ដំណាក់កាលទី១ មានរយៈពេល ០៦ខែ៖**</u> ជាដំណាក់កាលដំបូងដែលគណៈកម្មការអឺរ៉ុបនឹងធ្វើការពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ ដើម្បីស្វែងយល់បន្ថែមពីវឌ្ឍនភាពនៃការអនុវត្តកាតព្វកិច្ចក្នុងបទបញ្ញត្តិ លេខ 978/2012។

ដំណាក់កាលទី២ មានរយៈពេល ០៦ខែ៖ ក្នុងរយៈពេលនេះប្រសិនបើគណៈកម្មការអឺរ៉ុបពិនិត្យឃើញថាកម្ពុជាបានបង្ហាញពីវឌ្ឍនភាពនៃការងារទាក់ទងនឹងការព្រួយបារម្ភរបស់សហភាពអឺរ៉ុបនោះហើយ គណៈកម្មការអឺរ៉ុបយល់ថារបាយការណ៍នោះពិតជាមានវឌ្ឍនភាពគ្រប់គ្រាន់ នោះគណៈកម្មការនឹងទម្លាក់ចោលនូវចេតនាព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធ ហើយចេញសេចក្តីសម្រេចចិត្តបញ្ចប់នីតិវិធីនៅពេលនោះតែម្តង។ ក្នុងករណីដែលគណៈកម្មការអឺរ៉ុបមិនពេញចិត្តនឹងវឌ្ឍនភាពដែលកម្ពុជាបានបង្ហាញនោះ ក្រុមការងាររបស់គណៈកម្មការអឺរ៉ុបនឹងប្រើប្រាស់រយៈពេល ០៦ ខែនេះ ដើម្បីរៀបចំរបាយការណ៍ដែលអមជាមួយនឹងអនុសាសន៍របស់ខ្លួន សម្រាប់ជូនទៅគណៈកម្មការអឺរ៉ុបទាំងអស់ និងប្រធានគណៈកម្មការដើម្បីពិនិត្យ និងសម្រេចថាតើត្រូវព្យួរជាបណ្តោះអាសន្ននូវប្រព័ន្ធអនុគ្រោះពន្ធពីកម្ពុជា ឬយ៉ាងណា។ ប្រសិនបើ គណៈកម្មការទាំងអស់សម្រេចថាព្យួរប្រព័ន្ធអនុគ្រោះពន្ធពីកម្ពុជា នោះគឺត្រូវការរយៈពេល ០៦ខែទៀត ទើបសេចក្តីសម្រេចចុងក្រោយចូលជាធរមាន។ ក្នុងករណីនេះ ត្រូវចំណាយរយៈពេលសរុបចំនួន ១៨ ខែ គិតចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ នេះតទៅ។

**ចំណាត់ការនានាដើម្បីបង្ការផលប៉ះពាល់ជាអវិជ្ជមាន**

ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលអាណត្តិទី៦ នៃរដ្ឋសភា បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធបានធ្វើកំណែទម្រង់ស៊ីជម្រៅ ដែលបានជួយកាត់បន្ថយថ្លៃដើមផលិតកម្ម ដឹកជញ្ជូន និងលើកស្ទួយអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ច ដល់កម្មករ-កម្មការិនី និងកសិករ ព្រមទាំងប្រជាជនកម្ពុជាគ្រប់រូប។ ដោយឡែកក្រសួងពាណិជ្ជកម្មបានលុបចោលនូវការយកកម្រៃសម្រាប់គ្រប់គ្រងការនាំចេញ មិនតម្រូវឲ្យបង់កម្រៃនិងសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ និងបានរំកិលទីតាំងឈរជើងរបស់អគ្គនាយកដ្ឋានកាំកុងត្រូល ដែលកិច្ចការទាំងអស់នេះតម្រូវឲ្យរដ្ឋទទួលបន្ទុកពីការខាតបង់ចំណូលរាប់សិបលានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធកំពុងបន្តធ្វើកំណែទម្រង់សំដៅបង្កើនភាពប្រកួតប្រជែងនៃផលិតផលកម្ពុជា និងពង្រឹងឯករាជ្យភាពផ្នែកសេដ្ឋកិច្ច។

ក្រសួងពាណិជ្ជកម្មសង្ឃឹមថា សាធារណជនទាំងអស់ ទទួលបាននូវការស្រាយបំភ្លឺខាងលើ ហើយក្រសួងពាណិជ្ជកម្មនឹងបន្តផ្សព្វផ្សាយ និងគ្រោងរៀបចំកិច្ចពិភាក្សាតុមូល ដែលនឹងមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ក្នុងពេលឆាប់ៗខាងមុខ។

ក្រសួងពាណិជ្ជកម្ម ត្រៀមខ្លួនជានិច្ច ទទួលយករាល់សំណួរ និងមតិយោបល់នានាទាក់ទងនឹងបញ្ហាខាងលើ តាមរយៈគេហទំព័រ និងអ្នកនាំពាក្យរបស់ក្រសួង។

ថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩